# ដំឡូងជ្វា





គំរោងឥណទានកម្មវិធី ធនាគារ អភិវឌ្ឍន៍ អាស៊ី
(ADB) លេខ 1445-CAM ( SF )
នាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម
លេខ : ៣ ឆ្នាំ ២០០៣

## ១-សារៈសំខាន់របស់ដំឡូងជ្វា

ដំឡូងជ្វាជាដំណាំមើមមួយប្រភេទ ដែលកសិករនិយមដាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ មើមរបស់វា គេអាចយកទៅធ្វើអាហារសំរាប់ជំនួសបាយបាន ។ ម្យ៉ាងវិញទៀត គេអាចច្នៃ មើមដំឡូងជ្វាធ្វើជាបង្អែម ធ្វើជាតំណាប់ ។ល។ ដំឡូងជ្វា ជាដំណាំមួយប្រភេទ ដែលសម្បូរទៅដោយកាបូនអ៊ីដ្រាត ឬ ជាតិម្សៅ និងវីតាមីន "អា" ចំណែកទង និងស្លឹករបស់វា គេអាចយកទៅធ្វើជា បន្លែ និងចំណីសត្វបានយ៉ាងល្អ ។

ដំឡូងជ្វា គឺជាអាហារទ្រទ្រង់រាងកាយមួយមុខដ៏សំខាន់ផងដែរ ។ ព្រោះវាសម្បូរជាតិម្សៅដូចអង្ករដែរ វាអាចជួយជំនួសការខ្វះខាតស្បៀងបានម្តងម្កាលដោយការបរិភោគមើមដំឡូងជ្វា ។

## ២-ប្រភេទពូជ

ដំឡូងជ្វា មានពូជជាច្រើនប្រភេទ គេអាចបែងចែកពូជរបស់វាទៅតាម ទំរង់ស្លឹក ប្រវែង ដើមពណ៌របស់សំបក និងសាច់មើមដំឡូង។

*ពូជរបស់ដំឡូងជ្វាមានដូចតទៅ :*

### ក-ពូជល្ពៅ

ពូជនេះ ស្លឹករបស់វា មានលក្ខណៈផែកប្រហែលស្លឹកល្ហុងខ្មែរ សំបកមើម និងសាច់មានពណ៌លឿងខ្ចី ។



▶ ពូជដំឡូងថា " ល្ពៅ"

## ខ -ពូជហាវ៉ៃ

មានស្បែកពណ៌បៃតង មិនផែកខ្លាំង សំបកពណ៌ក្រហមភ្លាវ និងសាច់មើមពណ៌លឿងខ្ចី ។



▲ ពូជដំឡូងថា "ហាវ៉ៃ"

## គ -ពូជត្រួយស្វាយ

មានស្លឹកផែក សំបកមើម ពណ៌ក្រហម និង សាច់មើមពណ៌ស ។



ពូជដំឡូងថា "ត្រួយស្វាយ"

## ឃ-ពូជតៃនាង ៦៦

មានស្លឹកពណ៌បៃតងទ្រវែង សំបកមើមក្រហមចាស់ សាច់ពណ៌ទឹកក្រូច ។



ពូជដំឡូងជ្វា "តៃនាង ៦៦"

## ៣-បច្ចេកទេសដាំដុះ

### ៣.១-ការជ្រើសរើសដីនិងរដូវកាលដាំដុះ

ដំឡូងជ្វា ជាដំណាំប្រភេទយកមើម ដូច្នេះការជ្រើសរើសដីសំរាប់ដាំដុះ វាជាការសំខាន់ណាស់ ។ ដីដែលសមស្របសំរាប់ដំឡូងជ្វា គឺតំបន់ដីក្រហម ដីភ្នំ ដីល្បាប់ទន្លេ ឬ ស្ទឹង និងដីល្បាប់ខ្សាច់ ។ ចំណែកឯដីស្រែក៏អាចដាំដុះបានដែរ គឺដាំនៅបន្ទាប់ពីប្រមូលផលហើយ ។ ដំឡូងជ្វាគេអាចដាំបាននៅគ្រប់រដូវកាល ។ នៅរដូវភ្លៀងគេត្រូវដាំនៅលើដីទួល ឬ ដីមិនលិចទឹក និង ជាំទឹក ។ ពេលវេលាដែលល្អសមស្របសំរាប់ដាំដំឡូងជ្វា គឺនៅដើមរដូវភ្លៀង ។

### ៣.២-ការធ្វើដី

បើសិនអ្នកដាំដំឡូងនៅលើដីស្រែ ដែលទើបប្រមូលផលរួចអ្នកត្រូវភ្ជួរដីចោលឱ្យបាន ២សា ។ ១០ ថ្ងៃ បន្ទាប់មកអ្នកត្រូវបាចដី

លាមកគោមួយរទេះក្នុងផ្ទៃដី ១០ ម៉ែត្រការ៉េ រួចហើយអ្នកត្រូវរាស់ត្រឡប់ដីភ្លាម រួចទុកដីចោលរយៈពេល៣ថ្ងៃ ។ ក្រោយមកទៀតអ្នកត្រូវយកនង្គ័លភ្ជួរប្រណាមរងឱ្យបានជើងរង១ម៉ែត្រ *ខ្នងរង៧០ស.ម* រួចយកចបជួយថែមដីខ្លះទៀត ដើម្បីបំពេញដីរងឱ្យស្អាតល្អ ។ អ្នកមិនត្រូវធ្វើ រងតូចពេកទេ ពីព្រោះដំឡូងចុះមើមមិនបានល្អ ។ ដំឡូងផ្ទាជាដំណាំ ដែលមានឫសវែង ដូច្នេះ អ្នកគួរគប្បីភ្ជួរដីឱ្យបានជម្រៅប្រហែលពី *២០ ទៅ ៣០ស.ម* រួចហើយហាលដីឱ្យបាន *ពី ៧ ទៅ ១០ ថ្ងៃ* រួចច្របល់ ដីឱ្យបានសព្វល្អ ។



ការរៀបចំដី

## ៣.៣ -ការជ្រើសរើសទងសំរាប់ដាំ

អ្នកត្រូវជ្រើសរើសទងណា ដែលថ្លោស និងខ្ចីល្មម ហើយដែលមាន *អាយុពី ៤០ ទៅ ៥០ ថ្ងៃ* និង មានថ្នាំងញឹកល្អ ។ ប្រវែងទងដែលសមស្របល្អ សំរាប់ដាំនោះ គឺ មានប្រវែងពី *២០ ទៅ ៣០ ស.ម*

ហើយអ្នកមិនត្រូវយកទងណា ដែលមានឫសដុះច្រើន នៅតាមថ្នាំង នោះទេ ម្យ៉ាងវិញទៀតអ្នកត្រូវកាត់ស្លឹកនៅជាប់ទងចោលមួយចំនួន ប៉ុន្តែអ្នកត្រូវទុកខ្លះ ។



*ការជ្រើសទងដំឡូងសំរាប់ធ្វើពូជដាំបន្ត*

## ៣.៤-ការរក្សាពូជទុកសំរាប់ដាំ

ប្រសិនបើអ្នកដាំដំឡូងជ្វានៅរដូវសម្រក អ្នកត្រូវដាំពូជស្រាល ហើយត្រូវ *ត្រៀមពូជទុកតាំងពីខែកក្កដា* ដោយអ្នកគ្រាន់តែដាំដំឡូងទុក នៅលើដីទួល ឬ នៅតាមរានខ្ពស់ៗ ដែលដីមានជីជាតិល្អ ហើយមិនត្រូវឱ្យដំឡូងត្រូវកំដៅថ្ងៃពេកទេ គឺដើម្បីរក្សាដើមដំឡូងឱ្យនៅខ្ចីល្អ ដើម្បីទទួលបានផលច្រើន ។

## ៣.៥-វិធីដាំ

ការដាំដំឡូងជ្វា វាអាស្រ័យទៅតាមប្រភេទដី ប្រសិនបើដីល្អជាដីមាត់ទន្លេអ្នកអាចដាំបានពីរជួរ នៅលើរងមួយ ប៉ុន្តែបើនៅលើប្រភេទ

ដីស្រែអ្នកដាំតែមួយជួរ នៅលើរងមួយជាការល្អ ។ *ចន្លោះនៃការដាំពីដើមមួយទៅដើមមួយប្រវែងពី ៣០ ទៅ ៥០ ស.ម* ហើយចន្លោះពីរងមួយទៅរងមួយ គឺប្រវែង១ម៉ែត្រ ។ អ្នកត្រូវដាក់ទងដំឡូងកប់ដីឱ្យផ្អៀងប្រហែល ៤៥ ដឺក្រេ ដោយឱ្យចុងទងដំឡូងផុតពីដីមួយថ្នាំង ឬ ពីរថ្នាំង ។



*ចន្លោះនៃការដាំទងដំឡូងផ្កាលើដីលើកជារង*

## ៣.៦-ការថែទាំ

ការថែទាំវាជាការងារសំខាន់ណាស់ ដើម្បីទទួលបានទិន្នផលខ្ពស់ ។ នៅពេលអ្នកដាំដំឡូងរួចភ្លាមអ្នកត្រូវយកចំបើង ឬ ស្មៅក្រៀម ឬ កំប្លោកគ្របពីលើរងឱ្យជិត ដើម្បីការពារកុំឱ្យក្ដៅពេក ឆាប់ខ្សោះទឹកពីក្រោមដី ហើយម្យ៉ាងវិញទៀតដើម្បីការពារវល្លិដំឡូងកុំឱ្យប៉ះទៅនឹងដីនាំឱ្យវាចាក់ឫសច្រើន ។ បើសិនដំឡូងលូតខ្លាំងពេកអ្នកត្រូវឧស្សាហ៍បេះត្រួយ ឬ ក៏ត្រូវកាត់រំលែកដើមខ្លះ ដើម្បីឱ្យមើមរបស់វាថ្លោសល្អ ហើយអ្នកអាចយកដើមដែលកាត់នោះទៅធ្វើជាចំណីរបស់សត្វ ។ ទង

ដៃដំឡូងមិនត្រូវឱ្យវារលើសពី២ម៉ែត្រឡើយ ។ អ្នកមិនត្រូវស្រោចទឹកឱ្យជោគជាំពេកទេ ពីព្រោះវាអាចនាំឱ្យដីក្តាំង ។ បើរាំងភ្លៀងយូរពេក អ្នកត្រូវជ្រោយដីឱ្យម៉ដ្ឋ ពូនរងថែមឱ្យបានកំពស់ *៣០ ស.ម* ។ អ្នកត្រូវសំអាតស្មៅចោលពេលដំឡូងនៅតូច ហើយគួរជ្រួយពូនជុំវិញគល់ដើម្បីឱ្យដំឡូងចុះមើមល្អ ។ អ្នកត្រូវប្រុងប្រយ័ត្ននៅពេលជ្រួយដីមិនត្រូវអោយដាច់ឬសរបស់ដំឡូងឡើយ ពីព្រោះវាប៉ះពាល់ដល់ការចុះមើមរបស់ដំឡូង ។



*ការថែទាំចោចស្មៅលើរង*

## ៣.៧ -ការប្រមូលផល

អ្នកអាចប្រមូលផលដំឡូងជ្វាបាន នៅពេលដំឡូងជ្វាបានអាយុពី៩០ទៅ១៥០ថ្ងៃបន្ទាប់ពីដាំរួច ។ ម្យ៉ាងទៀតនៅពេលដំឡូងជ្វាជិតគ្រប់ខែប្រមូលផល អ្នកគួរគប្បីឧស្សាហ៍ឆ្កឹះគល់ឱ្យចំមើម ដើម្បីពិនិត្យមើល

មើមរបស់ដំឡូង ដើម្បីឱ្យដឹងថា តើមើមដំឡូងមានគីងស៊ីឬទេ បើគីងមិនទាន់ស៊ីមើមដំឡូងទេអ្នកអាចពន្យារពេលប្រមូលផលមួយរយៈទៀត ដើម្បីឱ្យមើមកាន់តែធំល្អ ។ ប្រសិនបើអ្នកដាំដំឡូងនៅរដូវប្រាំង អ្នកមិនត្រូវទុកឱ្យយូរពេកទេ ពីព្រោះវាអាចនាំឱ្យគីងស៊ីមើមរបស់ដំឡូង អ្នកអាចប្រមូលផលដំឡូងដោយគាស់នឹងចបចំពោះផ្ទៃដីតូចៗ បើអ្នកដាំជាលក្ខណៈចំការធំៗ អ្នកអាចប្រមូលផលដំឡូងដោយភ្ជួរ ហើយដើររើសមើមតែម្តង ។



*ការប្រមូលផលដំឡូងផ្វា*

## ៤_ជម្ងឺនិងសត្វល្អិត

ជម្ងឺដែលសំខាន់ចំពោះដំឡូងផ្វា ហើយតែងកើតជាញឹកញាប់នោះ គឺជម្ងឺក្រាស៊ីស្លឹក និងជម្ងឺមើមរលួយ ។ ចំណែកឯសត្វល្អិតវិញ គឺពពួកដង្កូវដំឡូងឫស គីងដំឡូង និង ចៃ ។